# *សិលាចារឹកពពេល K.៧១៩*

## *១- ព័ត៌មានទូទៅ*

*បើយោងតាមលោក ហ្សក៍ សឺដេស នៅក្នុងសៀវភៅ សិលាចារឹកនៃប្រទេសកម្ពុជា ក្បាលទី៦ ទំព័រទី៥២ បានសរសេរថា មានបំណែកសិលាចារឹកពីរចុះលេខ* K.*៧១៨ និង* K.*៧១៩ មានប្រភពចេញមកពីឃុំពពេល ខេត្តតាកែវ។ ប៉ុន្តែក្នុងសៀវភៅដដែលនោះ នៅទំព័រទី៣៧ លោកបានបញ្ជាក់ថាសិលាចារឹក* K.*៧៣ (ត្រូវនឹងសិលាចារឹក* K.*៧១៨) រកឃើញនៅវត្តព្រះធាតុ ក្បែរស្ទឹងព្រែកត្នោត ស្រុកកណ្ដាលស្ទឹង ខេត្តកំពង់ស្ពឺ*[១] *ទៅវិញ ដែលជាសាសនស្ថាន តាំងពីសម័យមុនអង្គរហូតមកដល់ចុងសតវត្សទី១២ និងដើមសតវត្សទី១៣ ក្នុងរាជ្យព្រះបាទស្រីជ័យវម៌្មទេវទី៧*[២]*។ នៅពេលនោះ សិលាចារឹកទាំងពីរត្រូវយកទៅរក្សាទុកនៅសារមន្ទីរជាតិកម្ពុជានារាជធានីភ្នំពេញ ចុះលេខ* D.*៦៦ និង* D.*៦៧។ ផ្ទាំងសិលាចារឹក* K.*៧១៨ និង* K.*៧១៩ ក្រោយពីផ្លាស់ប្តូរទីកន្លែងប៉ុន្មានលើកមក ចុងក្រោយក៏យកមករក្សាទុកនៅសារមន្ទីរជាតិកម្ពុជាវិញ។ ដោយសារអត្ថបទចារឹកនេះជាបញ្ជីតង្វាយ លោក សឺដេស មិនបានប្រែសម្រួលសិលាចារឹកទាំងពីរជាភាសាបារាំងឡើយ គឺគ្រាន់តែបានសង្ខេបអត្ថន័យរបស់សិលាចារឹកនីមួយៗប៉ុណ្ណោះ។ ក្រោយមកទៀត លោក ហ្វីលីព ចេណ្ណឺរ បានសិក្សាសិលាចារឹក* K.*៧១៩ ដោយផ្អែកលើអំណានរបស់លោក សឺដេស និងប្រែសម្រួលជាភាសាអង់គ្លេសនៅក្នុងស្នាដៃរបស់លោក Part* xml, № 85 *និងចុះផ្សាយក្នុងគេហទំព័រ* http://sealang.net/ok/corpus.htm*។*

*សិលាចារឹក* K.*៧១៩ មានកម្ពស់៤៥ស.ម. បន្ទារ៣៨ស.ម*[៣]*។ អត្ថបទចារឹកនេះចារជាភាសាខ្មែរសម័យមុនអង្គររវាងឆ្នាំ៥៧៨-៦៧៧*[៤] *មានចំនួន១២បន្ទាត់ គែមសងខាងនៃ*

---

*[១] បច្ចុប្បន្នស្ថិតនៅសង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ។*

*[២] ហ៊ុន ឈុនតេង, ២០២៣ ក្នុង* https://ams.com.kh/khmercivilization/detail/28997*។*

*[៣] សឺដេស, ១៩៥៤។*

*[៤] ចេណ្ណឺរ; សឺដេស, ១៩៥៤ កំណត់អាយុសិលាចារឹកនេះនៅសតវត្សទី៧។*

*អត្ថបទដោយៈ ហ៊ុន ឈុនតេង និង ប៉ោ សុខរិន*

*ផ្ទាំងថ្មខូចខាតធ្វើឱ្យដាច់តួអក្សរខាងដើមនិងខាងចុងគ្រប់បន្ទាត់ ដែលនាំឱ្យបាត់ព្រះនាមរបស់ទេពផងដែរ។ យ៉ាងនេះក្ដី យើងអាចស្គាល់ព្រះនាមទ្រង់បាន តាមរយៈសិលាចារឹក K.១២៧៩ ដែលអាចបំពេញត្រង់ចំណុចដែលបែកនោះបាន។ ទេពអង្គនេះ គួរតែមានព្រះនាមថា «ស្រីគោកណៅ៍សូរ (គ្រីគោកណ្ណៅ៍គ្វរ)» ដែលជាព្រះនាមរបស់ព្រះឥសូរក្នុងទម្រង់ជា «សិវលិង្គ»[៥]។ ទោះបីជាឃ្លាខាងដើមបានបាត់បង់ហើយក៏ដោយ ប៉ុន្តែតាមរយៈសេចក្ដីដែលនៅសល់ យើងអាចយល់ថាជាការរៀបរាប់ពីតង្វាយរបស់មនុស្សម្នាក់ឈ្មោះ «មេងអញ»[៦] ថ្វាយដល់ប្រាសាទព្រះគម្តែងអញស្រីគោកណៅ៍សូរ មានដូចជាអ្នកបម្រើប្រុសស្រី ដើមស្វា ដើមដូង និងស្រែ។*

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

*១- [[អំនោយ៑]]មេង៑អញ៑អាយ៑តវ្រះកំម្រតាង៑អ[ញ៑]][គ្រី]]*

*២- [[គោក]]ណ្ណៅ៍គ្វរក្ញុំ[៧]តសិវាក្ញាសិ១វាតឯតិ១វាទគ[[មី១]]...*

*៣- [[វា]](ត)ន្ទង៑១វាក្ទុង៑១វាសំរោក១វាសំតោះ[៨]១វាច្ទេ[[១]]...*

*៤- [[វា]](រ)ង៑ហ្វញ៑[៩]១វាត្វេក៑១វាអំបិក៑១វាសលិភិត...*

---

[៥] *សូមអានបន្ថែម៖* https://ams.com.kh/khmercivilization/detail/12677

[៦] *អត្ថបទសិលាចារឹកនេះដាច់នៅខាងដើម គឺអាចប៉ះពាល់ដល់ឈ្មោះម្ចាស់ទានរូបនេះ ប៉ុន្តែតាមសំណល់ឃ្លាដែលដាច់ យើងយល់ថា «មេង៑អញ៑» គឺជាឈ្មោះរបស់ម្ចាស់ទាននេះតែម្ដង។*

[៧] *ពាក្យត្រឹមត្រូវជា «ក្ញុំ»។ អ្នកចារប្រហែលភ្លេចស្រៈ «ុ» (?) ប៉ុន្តែករណីបែបនេះ ក៏សង្កេតឃើញមានក្នុងសិលាចារឹកដទៃទៀតដែរ។ តើករណីទាំងនោះ សុទ្ធតែបណ្ដាលមកពីអ្នកចារ ចារភ្លេចសញ្ញាស្រៈ «ុ» ទាំងអស់ឬ?*

[៨] *អំណានពាក្យនេះអាចអានម្យ៉ាងទៀតជា «សំរោះ» ប៉ុន្តែលោក សឺដេស អានជា «សំតោះ» ដ្បិតលោកបានឃើញស្នាមចុចបន្តជាខ្សែ ដែលអ្នកចារមិនបានចារសាច់ថ្មឱ្យជ្រៅទៅជាអក្សរ «ត» ។ បើយើងអានសំណេរនោះជា «សំរោះ» នោះតួអក្សរ «រ» ហាក់មានទម្រង់ចម្លែកបន្តិច។ ត្រង់ចំណុចនេះពិបាកនឹងអះអាងឱ្យដាច់ស្រេចថាជា «សំតោះ» ឬ «សំរោះ» ណាស់ ប៉ុន្តែយើងសង្កេតឃើញថា នរនាម «សំតោះ» ឃើញមាននៅក្នុងសិលាចារឹកដទៃទៀតក្រៅពីសិលាចារឹកនេះ ចំនួន៩ដង។ យើងពុំធ្លាប់ឃើញនរនាម «សំរោះ» ឡើយ ឃើញតែ «អំរោះ» និង «ចំរោះ» ដែលអាចមានឫសចេញមកពីពាក្យ «រោះ»។*

[៩] *លោក សឺដេស អានជា «រង៑ហ្វញ៑»។ លោក ចេណ្ណឹរ ប្រហែលច្រលំអានជា «រង៑ហ្វង៑»។*

*អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ោ សុខរីន*

៥- ...(ន្ទា)និ[១០]១វាច្នោងឹ១វាក្វងឹអរសិ១កុក្មោចិ១កុ...

៦- ...១កុប្រេមាវលិ១កុនយនាវលិ១កុវត្នាវលិ១កុស[១១]...

៧- ...រុ១កុសេងឹនាកាចនិ១កុស្វរ៑កុស្រកុណ្ឌលា[១២]១កុ...

៨- ...(ឆៅ)[១៣]១កុគារិកា១កុនិម្ពុរ១កុអទុះ[១៤]១កុតំនរ៑១កុ...

៩- ...រិកា១កុត្រៃ១កុវញ១កុមរាវលិ១កុមុលិះ...

១០- [[កុ]](ចុ)ងឹហ្វាយ៑[១៥]១កុប្បោងឹ១កុមញ្ចុកា១កុសុ...

១១- [[កុ]]វេ្វ១[១៦]កុវ្ញចិតរុ១ស្វាតំ២០០-១តោងឹតំ...

១២- ...ប្រៀសិស(ទ្រែ)[១៧]១បាទ...

## ៣- អត្ថបទប្រែសម្រួល

(១-២) (តង្វាយ)មេងអញថ្វាយដល់(ប្រាសាទ)ព្រះគម្តែងអញស្រីគោកណៅស្វូរ។

(២-៥) អ្នកបម្រើប្រុស(មាន) វាក្មាស១ វាតឯត១ វាទសមី(១) ... (វា)តន្វង១ វាក្នុង១ វាសំរោក១ វាសំតោះ១ វាច្កេ... (វា)រងហ្វញ១ វាត្វេក១ វាអំបិក១ វាសលភិត... (វា)...ន្ទាន១ វាច្នោង១ វាក្វងអរស១

(៥-១១) (អ្នកបម្រើស្រីមាន) កុក្មោច១ កុ...១ កុប្រេមាវលិ១ កុនយនាវលិ១ កុវត្នាវលិ១ កុស...រុ១ កុសេងនាកាចន១ កុស្វរ(១) កុស្រកុណ្ឌលា១ កុ... ឆៅ១ កុសារិកា១ កុនិស្ពុរ

---

[១០] លោក សឺដេស និងលោក ចេណ្ណឺរ អានជា «ន្ទានិ»។

[១១] លោក សឺដេស និងលោក ចេណ្ណឺរ មិនអាន «ស»។

[១២] សញ្ញាជើងឌ «ៈ្ឌ» ក្នុងសិលាចារឹកនេះ ស្ទើរតែប្រទ្បំនឹងជើងទ «្ទ»។ ករណីបែបនេះ មានច្រើននៅក្នុងសិលាចារឹកនានា។ ជាទូទៅ ជើងឌ «្ឌ» វែងជាងជើងទ «្ទ»។

[១៣] លោក សឺដេស និងលោក ចេណ្ណឺរ អានជា «ៅ» ប៉ុណ្ណោះ។

[១៤] លោក សឺដេស និងលោក ចេណ្ណឺរ អានជា «អំទុះ»។

[១៥] លោក សឺដេស និងលោក ចេណ្ណឺរ អានត្រឹម «ងហ្វាយ៑» ប៉ុណ្ណោះ។

[១៦] លោក សឺដេស និងលោក ចេណ្ណឺរ មិនអាន។

[១៧] លោក សឺដេស និងលោក ចេណ្ណឺរ អានជា «ារិ សរេ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង និង ប៉ៅ សុខរីន

១ កុអទុះ១ កុតំនរ១ កុ...រិកា១ កុត្រែ១ កុវញ១ កុមរាវលិ១ កុមុលិះ (កុ)ចុងហ្វាយ១ កុប្បោង១ កុមញ្ជុកា១ កុសុ... (កុ)វេ១ កុរ្វចតរុ១

(១១-១២) ស្វា២០១ដើម ដូង...ដើម ...ព្រៀស ១សន្រែ ...បាទ...

## ៤- សន្និដ្ឋានរួម

សិលាចារឹកមានប្រកពចេញមកពីពពេល ផ្តល់សារៈសំខាន់ផ្នែកទិដ្ឋភាពជំនឿនិងជីវភាពឬដំណើរប្រព្រឹត្តិទៅនៃសហគមន៍ប្រាសាទក្នុងសង្គមខ្មែរសម័យបុរាណ ពុំខុសពីសិលាចារឹកភាសាខ្មែរមុនអង្គរដទៃទៀតទេ។ ការពិនិត្យផ្ទៀងផ្ទាត់អំណានឡើងវិញ នាំឱ្យបានបើកផ្លូវឱ្យយើងកាន់តែស្វែងយល់និងបំពេញនូវចន្លោះខ្វះខាត ដែលពុំអាចយល់បាននៅក្នុងការសិក្សាមុនៗ។

## ៥- វាក្យសព្ទ

| | |
|---|---|
| **វ្រះកំម្រតាងអញ** | គោរម្យងារព្រះក្នុងព្រហ្មញ្ញសាសនា ព្រះក្នុងព្រះពុទ្ធសាសនា និងព្រះមហាក្សត្រ[១៨]។ |
| **ក្ញុំ** | (~ក្ញុំ) > ខ្ញុំ= អ្នកបម្រើ។ |
| **សិ** | ពាក្យសម្គាល់មនុស្សប្រុសទូទៅ។ |
| **វា** | ពាក្យសម្គាល់អ្នកបម្រើភេទប្រុស។ |
| **កុ** | ពាក្យសម្គាល់អ្នកបម្រើភេទស្រី។ |
| **តំ** | > ដើម។ |
| **តោង៑** | > ដូង។ |
| **សន្រែ** | ខ្នាតស្រែ។ |
| **បាទ** | (សំ.) ខ្នាតរង្វាស់ដី។ |

[១៨] ឡុង សៀម, ១៩៩៦។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ោ សុខវីន

# បញ្ជីឯកសារ

ឡុង សៀម. (១៩៩៦). នរនាម និងឋានន្តរនាម តាមសិលាចារឹកកម្ពុជា សម័យមុនអង្គរ (សតវត្សទី VI ដល់ VIII). កម្ពុជសុរិយា (ឆ្នាំទី៥០ លេខ២). ភ្នំពេញ.

Cœdès, George. (1954). Inscriptions de Popél. In *Inscriptions du Cambodge* (Vol. VI, pp. 52-53). Paris: Editions de Boccard.

## គេហទំព័រ

http://sealang.net/ok/corpus.htm

https://ams.com.kh/khmercivilization/detail/28997

# បញ្ជីរូបភាព



អត្ថបទចម្លងសិលាចារឹកពពេល K.៧១៩ (ចម្លងដោយ៖ ហ៊ុន ឈុនតេង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ៅ សុខរីន



រូបថតសិលាចារឹកវត្តពពេល K.៧១៩ (រូបថត៖ EFEO_ CAM19806-3)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ៅ សុខរីន